មជ្ឈមណ្ឌលជាតិនៃជនពិការ
National Centre of Disabled Persons
Trapeang Svay Village, Sangkat Phnom Penh Thmei, Khan Sen Sok,
Phnom Penh, Cambodia. P.O Box: 170, Postal Code: 12101, Tel: (855) 88 90 53 528
E-mail: ncdp_cambodia@ncdpcam.org
Website: http://www.ncdpcam.org

# របាយការណ៍

## មជ្ឈមណ្ឌលជាតិនៃជនពិការ ក្នុងឱកាសសន្និបាតបូកសរុប
## និងការងារបណ្ដាញកម្មវិធីស្ដារលទ្ធភាពពលកម្មតាមសហគមន៍លើកទី១៣

ភូមិត្រពាំងស្វាយ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៤





















## ១. <u>សេចក្តីផ្តើម</u>

មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវបានបង្កើតឡើងដោយសេចក្តីប្រកាសរបស់ក្រសួងសង្គមកិច្ចលេខ ៧៥៧ សកអ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៧ និងត្រូវបានសម្ពោធន៍ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៩៧។ មជ្ឈមណ្ឌលជាតិនៃជនពិការ (មជជព) មានទីតាំង ស្ថិតនៅអគារលេខ ៣ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បច្ចុប្បន្នត្រូវបានផ្លាស់មកភូមិត្រពាំងស្វាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

មជ្ឈមណ្ឌលជាតិនៃជនពិការ ដែលត្រូវបានសាងសង់រួចត្រៀមសម្ពោធន៍ជាផ្លូវការនៅឆ្នាំ ២០១៤ នេះ ជាអំណោយ និងស្ថាបនិក ឡើងដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតឌ** អគាររដ្ឋបាលថ្មីរបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវបានសាងសង់នៅលើផ្ទៃក្រឡា ទំហំ ៥០០០ម៉ែត្រក្រឡា អគារទំហំទទឹង ២០ម៉ែត្រ,

បណ្តោយ ២៥ម៉ែត្រ និងកម្ពស់ ១ជាន់ ហើយបានការឧបត្ថម្ភគាំទ្រ និង បានថវិកាពីក្រុមហ៊ុនទ្រីភាព, ម្ចាស់ជំនួយ និង សប្បុរសជន ផ្សេងទៀត។

មជ្ឈមណ្ឌលជាតិនៃជនពិការ បាននឹងកំពុងផ្តល់សេវាកម្មជូនជនពិការនៅ ថ្នាក់ឃុំ រាជធានី/ខេត្ត/ក្រុង តាមការ អនុវត្ត កម្មវិធី មានដូចតទៅ:

- កម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍ (ជួយជនពិការផ្នែកសុខភាព អប់រំ មុខរបរខ្នាតតូច និងពង្រឹងសិទ្ធិ តាមរយៈ ច្បាប់ស្តីអំពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ)។
- កម្មវិធី សេវាពតិមាននិងទំនាក់ទំនង (រកការងារធ្វើជូនជនពិការ និងបញ្ជូនជនពិការទៅរកសេវាកម្មទូទៅ)
- គ្រោងការលក់សម្ភារៈសិប្បកម្ម (លក់ បណ្តុះបណ្តាល និងចែកចាយសិប្បកម្មធ្វើសូត្រដោយបងប្អូនជនពិការ)
- កម្មវិធី វេទិការជនពិការ (ពង្រឹងសមត្ថភាព បងប្អូនជនពិការតាមរយៈបណ្តាញសាពតិមាន)

## ២. លទ្ធផលរួម

បច្ចុប្បន្នមជ្ឈមណ្ឌលជាតិនៃជនពិការ មានជនពិការជាសមាជិក និងកំពុងទទួលផលសរុបចំនួន ២៣,៣៧៥នាក់ និងមានសមាជិក ចូលរួមជាសកម្មជួយដល់ជនពិការ ១១៦,៨៧៥នាក់។ កម្មវិធី មជជព គ្របដណ្តប់ទៅលើ ខេត្ត/ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា និងបាន បោះទីតាំងជាអចិន្ត្រៃយ៍ក្នុងខេត្តចំនួន៧គឺ ខេត្តកណ្តាល កំពង់ស្ពឺ កំពត តាកែវ ក្រុងព្រះសីហនុ រតនគីរី និងរាជធានីភ្នំពេញ។

តាមរយៈកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍ បានបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ជនពិការតាមសហគមន៍ (គអជស) ចំនួន ៣៣ឃុំ ដែលបាននឹងកំពុងផ្តល់សេវាជូនជនពិការលើវិស័យ អប់រំ សុខភាព បង្កើនមុខរបរ និងពង្រឹង ជីវភាពរស់នៅស្របតាមច្បាប់ស្តីអំពីកិច្ចការពារ និងលើកម្ពស់សិទ្ធិជនពិការសរុបជនពិការ ៣,៣៧៥នាក់ ក្នុងនោះមាននារី ១,៤៥៥នាក់។ គណៈកម្មាធិការ អភិវឌ្ឍន៍ ជនពិការតាមសហគមន៍ ត្រូវបានបង្កើតឡើង និងដឹកនាំដោយ ជនពិការ ក្រោមការប្រឹក្សាជាក្រុមប្រឹក្សាភិបាលរបស់រដ្ឋអំណាចមូលដ្ឋានមាន អភិបាលស្រុក លោកមេឃុំ មេភូមិ និង ស្ថាប័នអង្គការពាក់ព័ន្ធជាច្រើនទៀត។

កម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍ បានបន្តកិច្ចសហប្រតិបត្តិការជាដៃគូរក្នុងការអនុវត្តការងាររួមមាន:

- ក្រុមប្រឹក្សាសកម្មភាពជនពិការ
- មន្ទីរពេទ្យសុខភាពផ្លូវចិត្តកុមារ CCAMH
- អង្គការទាហានជើងចាស់អន្តរជាតិ VI
- មណ្ឌលស្តារខេត្តកំពង់ស្ពឺ ICRC
- អង្គការកម្ពុជាត្រាស្ត CT ភ្នំពេញ និងព្រះសីហនុ
- មន្ទីរពេទ្យផ្សារដើមថ្កូវ
- មន្ទីរពេទ្យរុស្សី
- មន្ទីរពេទ្យគន្ធបុប្ផា
- មន្ទីរពេទ្យកាលម៉ែត
- មជ្ឈមណ្ឌលវះកាត់កុមារ CSC
- មណ្ឌលសុខភាពឃុំ ក្នុងឃុំគោលដៅ

ក្រៅពីកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍ កម្មវិធីសេវាពតិមាន និងទំនាក់ទំនង បានគ្រប់គ្រងដោយចុះ បញ្ជីជនពិការចំនួន ២០,០១៦នាក់ ក្នុងនោះមាននារី ៨,០១៦នាក់។ បច្ចុប្បន្នបងប្អូនទាំងនោះបានបញ្ជូនទៅរកការងារ ធ្វើចាប់តាំងពីឆ្នាំ ១៩៩៧ មកទក ទល់បច្ចុប្បន្នសរុបចំនួន ៣១៩២នាក់, ស្រី ២៧៥៣នាក់ និងកំពុងបន្តការងារនៅតាម ស្ថាប័ន រោងចក្រ និងសហគ្រាសផ្សេងៗចំនួនសរុប។ ក្នុងនោះកម្មវិធីបានបញ្ជូនជនពិការទៅរកសេវា និងទទួលបានសេវា ដូចតទៅ:

- **សេវាសុខភាពជូនជនពិការ**
  - មន្ទីរពេទ្យកាលម៉ែតតាមរយៈ ឯកឧត្តមវេជ្ជបណ្ឌិតឈ្មោះ ឈៀង រ៉ា ផ្តល់ការអនុគ្រោះ ដោយមិនគិតប្រាក់ដល់ នារី ពិការ ឆ្លង ទន្លេ បានចំនួនសរុបចំនួន ៤៤នាក់។
  - ជួយស្ត្រីពិការឆ្លងទន្លេទៅមន្ទីរពេទ្យគាំពារមាតា និងទារក សរុបចំនួន ៥២នាក់
  - ជនពិការទទួលបានការពិនិត្យ និងព្យាបាលភ្នែកនៅ អង្គការ CDMD សរុបចំនួន ៤៦នាក់
  - ជនពិការទទួលបានការពិនិត្យ និងព្យាបាលជម្ងឺទូទៅ និងវះកាត់នៅ Center of Hope សរុបចំនួន ៨៨នាក់
  - ជនពិការទទួលបានការពិនិត្យ និងព្យាបាលជម្ងឺទូទៅ និងវះកាត់នៅ Emergency សរុបចំនួន ១០នាក់
  - ជនពិការទទួលបានរទេះរុញ ពិនិត្យភ្នែក និងត្រចៀកនៅ JSC សរុបចំនួន ១៨នាក់
  - ជនពិការទទួលបានថ្នាំពន្យាជីវិតជម្ងឺអេដសន៍ Maryknoll សរុបចំនួន ៥នាក់
  - ជនពិការទទួលបានសេវាពិគ្រោះយោបល់ និងថ្នាំជម្ងឺផ្លូវចិត្តនៅ TPO សរុបចំនួន ៨នាក់
  - ជនពិការទទួលបានការពិនិត្យ ព្យាបាល និងវះកាត់ភ្នែកនៅ Rose Charity សរុបចំនួន ១០១នាក់
  - ជនពិការទទួលបានវ៉ែនតាតាមរយៈគម្រោងអភិវឌ្ឍន៍គំហើញសរុបចំនួន ១,៧៩៦នាក់ ។ កម្មវិធីនេះបាន ការឧបត្ថម្ភ ពីរ សាកលវិទ្យាល័យ UC Beckley សមាគមន៍ថែរក្សាភ្នែកប្រទេសកូរ៉េ តាមរយៈ វេជ្ជបណ្ឌិត CHU សមាគមន៏និស្សិត ស្ម័គ្រចិត្ត ប្រទេសកូរ៉េ HUG និងអ្នកស្ម័គ្រចិត្តមកពីសហរដ្ឋអាមេរិចលោក Tramell COX។ កម្មវិធីនេះបានបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត ៣រូបនៅ មជជព និងបន្តចែកជូនវ៉ែនតាដោយឥតគិតថ្លៃ។
- **សេវាស្តារការយសម្បទា**
  - ជនពិការទទួលបានជើងដៃសិប្បនិម្មិតនៅអង្គការកម្ពុជាត្រាស់ចំនួន ២៧៥នាក់
  - ជនពិការទទួលបានជើងដៃសិប្បនិម្មិត រទេះរុញជនពិការ និងព្យាបាលដោយចលនានៅ មជ្ឈមណ្ឌលស្តារ លទ្ធភាពពលកម្ម គៀន ឃ្លាំងសរុបចំនួន ២៨៤នាក់
- **សេវាអប់រំ និងបណ្តុះបណ្តាល**
  - ជនពិការសរុបចំនួន ២២៩នាក់, ស្រី ៧៣នាក់ ទទួលបានអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិតពី **សម្តេច អគ្គមហា សេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត**
  - ជនពិការសរុបចំនួន ២៩៧នាក់, ស្រី ៨៣នាក់ ទទួលបានអាហារូបករណ៍ថ្នាក់បរិញ្ញាបត្ររង, បរិញ្ញាបត្រ និងអនុបណ្ឌិត តាម បណ្តាល សាកលវិទ្យាល័យ រាជធានី/ខេត្ត/ក្រុង
  - ជនពិការសរុបចំនួន ៣,៣៦៦នាក់, ស្រី ២,៣២១នាក់ ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ
  - ជនពិការសរុបចំនួន ៣,១៩២នាក់, ស្រី ២,៧៥៣នាក់ ទទួលបានឱកាសការងារ នៅតាមស្ថាប័នជាតិ ក្រុមហ៊ុន, រោងចក្រ និង សហគ្រាស។

- ក្រៅពីការងារខាងលើនេះ កម្មវិធីបានបើកវគ្គបណ្តុះបណ្តាល, វគ្គបណ្តុះបណ្តាលរកការងារធ្វើ, ថែរក្សា ការងារ វិធីសាស្ត្រពង្រឹងសមត្ថភាព និងជំនឿជាក់លើខ្លួនឯង, ជំនួញខ្នាតតូច និងចុះបណ្តុះបណ្តាលលើក ទឹកចិត្តដល់ជនពិតាមរកចក្រ សហគ្រាស ដែលបានយកបងប្អូនជនពិការទៅបំរើការងារ។ កម្មវិធីសូមថ្លែង អំណរគុណដល់ក្រុមហ៊ុន សហគ្រាស ដែលបាន សហការរួមមានៈ
  - ក្រុមហ៊ុនឃុនម៉េងថ្មៃត្បូង
  - រោងចក្រផលិតស្បែកជើង វីជេន ហ្វូតវែរ (ខេមបូឌា) ខូអិលធីឌី
  - អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា
  - ស្ថានទូតអូស្ត្រាលី
  - ក្រុមហ៊ុនទូរស័ព្ទចល័តស្មាត
  - ក្រុមហ៊ុនទូរស័ព្ទចល័តសែលកាត
  - ក្រុមហ៊ុនម៉ាស៊ីនត្រជាក់តុលឡាយ
  - ក្រុមហ៊ុនការហ្វេហេបភី
  - អង្គការ ADD

គ្រោងការលក់ និងចែកចាយសម្ភារៈសិប្បកម្មរបស់ជនពិការ បានផ្តល់ការងារជូនស្ត្រីពិការតាមសហគមន៍ ដែល អាចបង្កើន ជីវភាពរស់នៅរបស់គ្រួសារជនពិការប្រមាណ ១,៣០០គ្រួសារ។ តាមរយៈការផលិតសិប្បកម្មដោយដៃនេះបាន លើកកម្ពស់ស្នាដៃ និង លទ្ធភាពរបស់បងប្អូនពិការ និងលើកកម្ពស់វប្បធម៌ខ្មែរតាមរយៈការប្រើប្រាស់រូបធាតុក្នុងស្រុកដូច ជា សូត្រ ឈើ វល្លិ៍ និងថ្ម ជាដើម។

មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល ឯកឧត្តម សែម សុខា និងនាយកប្រតិបត្តិ ឯកឧត្តម យឹ វ៉ាសនា និងបុគ្គលិកនាយចាត់ការ ដែលដឹកនាំអនុវត្តកម្មវិធីសរុបចំនួន ៣៤នាក់ និងអ្នកស្ម័គ្រចិត្តនៅការិយា ល័យកណ្តាល នៅតាមឃុំ និងតាមភូមិសរុបចំនួន ២៧៤។

នៅក្នុងចន្លោះឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៤នេះ ការិយាល័យរដ្ឋបាល និងធនធានរបស់ខ្លួនបានប្រឹងប្រែង និង ចំណាយ ពេល ក្នុង ការសាងសង់ មជជព ថ្មីស្ថិតនៅលើទីតាំងដែលមានទំហំដី ៥០០០ម៉ែត្រការ៉េ និងត្រៀមបានបញ្ចប់ ការងារជាស្ថាពរនៅក្នុងខែកុម្ភៈ ឆ្នាំ ២០១៤នេះ ។ មជជព ថ្មីនេះត្រូវបានផ្តួចផ្តើមស្ថាបនាឡើងដោយស្ថាបនិក និង អំណោយផ្ទាល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ការឧបត្ថមគាំទ្រ និងបានថវិកាពីក្រុមហ៊ុនទ្រីភាព, ម្ចាស់ជំនួយ និងសប្បុរសជនផ្សេងទៀត។

## ៣. ម្ចាស់ជំនួយ

### ម្ចាស់ជំនួយមុន

១. ស្ថានទូតការណាដា

២. ស្ថានទូតជប៉ុន

៣. ស្ថានទូតអូស្ត្រាលី

៤. ក្រុមហ៊ុនស្រាបៀរថៃហ្គឺ មូលនិធិ លីលាន (Lylian Fund)

៥. ក្រុមហ៊ុន ត្រេនស្គូ នៅប្រទេសអង់គ្លេស

៦. ឡាយអិនក្លិបស៊ីងហ្គាពួរ (Lion Club Singapore)

៧. កាកបាទក្រហមអាមេរិច (American Red Cross / USAID)

៨. មូលនិធិស្តារលទ្ធភាពពលកម្មពិភពលោក (WRF)

៩. អុីកូ (ICCO)

១០. យូនីសេហ្វ (UNICEF)

១១. មូលនិធិអូស្ត្រាលី (Kangaroo Fund)

១២. អង្គការ JLDD

១៣. UNDP

១៤. Adopt-A-Minefield

១៥. កម្មវិធីអភិវឌ្ឍន៍តំបន់ទន្លេមេគង្គ (MPDF)

១៦. ធនាគារពិភពលោក (World Bank)

១៧. កូរ៉េ (Korea Fund)

**ម្ចាស់ជំនួយបច្ចុប្បន្នមានៈ**

១. Baptist World Aid Australia (BWAA)

២. Transform Aid International (TAI)

៣. Kangaroo Fund

៤. Choo Young Moo Fund

៥. Korea Baptist Church

៦. និងសប្បុរសជនផ្សេងៗ

## ៤. សេចក្តីថ្លែងអំណរគុណ

មជជព ថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនា បតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា-បុត្រី, ក្រសួងសង្គមកិច្ច, ក្រសួង អប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ទីស្តីការ គណៈរដ្ឋមន្ត្រី, ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ, ក្រសួងមហាផ្ទៃ, ក្រសួងទេសចរណ៍ វិទ្យាស្ថាន និងអង្គ ការនានាជាច្រើនទៀត ដែលបានបំពេញភារកិច្ចជាមួយ មជជព ដើម្បីជួយដល់បងប្អូនជនពិការនៅក្នុងតំបន់ មជជព គ្រប់គ្រងបានរស់នៅប្រកបដោយ សេរីភាព សុភមង្គល និងសេចក្តីថ្លៃថ្នូរ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៤

**នាយកប្រតិបត្តិ មជជព**

**យី វាសនា**